ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៥៥៧ / ០៨.៩.២០០៩
សាលដីកា
លេខ: ៨៤ ក្រ.III.ស/២៨.៦.២០១២

**************

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងទាស់ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៥៥៧ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ រវាង ៖

ជនជាប់ចោទឈ្មោះ [redacted] គឹមហូ ភេទស្រី អាយុ៤៦ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្ន[redacted]ស្រុកបន្ទាយមាស ខេត្តកំពត ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ[redacted] (រ) ប្តីឈ្មោះ[redacted]មានកូន០៥នាក់ ទោសពីមុនគ្មាន។

ជាប់ចោទពីបទ: ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅ ភូមិត្រាំសសរ ឃុំសំរោងលើ ស្រុកបន្ទាយមាស ខេត្តកំពត កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទី ភេទស្រី អាយុ៥៨ឆ្នាំ ជាតិខ្មែរ បច្ចុប្បន្នរស់នៅ ភូមិត្រាំសសរ ឃុំសំរោងលើ ស្រុកបន្ទាយមាស ខេត្តកំពត។

**ឯដំណើររឿងមានដូចតទៅ ៖**

កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨ វេលាម៉ោង៥ល្ងាច ឈ្មោះ [redacted]ទី បានរើសវ៉ាន់ពីតូបរបស់ខ្លួន



Scanned with CamScanner

ទៅផ្ទះ ស្រាប់តែឈ្មោះ [redacted] គឹមហូ បានយកស័ង្កសី វាយបិតគូបរបស់ឈ្មោះ [redacted] ទី ដែលបានទិញពីឈ្មោះ [redacted] មុំ មានទីតាំងស្ថិតនៅផ្សារត្រាំសសរ ភូមិត្រាំសសរ ឃុំសំរោងលើ ស្រុកបន្ទាយមាស ខេត្តកំពត គឺក្នុងគោលបំណងមិនឲ្យឈ្មោះ [redacted] ទី ចូលលក់ដូរតវ៉ាន់។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៩៩ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] គឹមហូ ភេទស្រី អាយុ៤៦ឆ្នាំ ដាក់ពន្ធនាគារកំណត់៦ខែ (ប្រាំមួយខែ) តែទោសនេះត្រូវអនុវត្ត គឺ

- ទោសគុកគិតពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៩ ដល់ត្រឹមថ្ងៃដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩។

- ទោសដែលនៅសល់ ត្រូវព្យួរទាំងអស់ ទុករយៈពេលសាកល្បង ចំនួន ០៥ឆ្នាំ គិតពីថ្ងៃប្រកាសសាលក្រម។

២- បង្គាប់ឲ្យឈ្មោះ [redacted] គឹមហូ ចេញសំណងអន្តរាយ និងជម្ងឺចិត្ត សរុប ចំនួន៣.០០០.០០០រៀល (បីលានរៀល) ឲ្យដល់ឈ្មោះ [redacted] ទី ជាដើមបណ្តឹងរដ្ឋប្បវេណី ការទាមទារលើសពីនេះបដិសេធចោល។

៣. សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គឹមហូ និងចំពោះមុខជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទី។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] គឹមហូ ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩៩ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកំពត គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៥០ ក្រ.III.ស ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] គឹមហូ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៩៩ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកំពត ទុកជាបានការពេញទាំងមូល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ ប្រកាសជាសាធារណៈ នៅថ្ងៃ ទី២២ ខែកក្កដា ឆ្នាំ២០១១ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។



Scanned with CamScanner

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ជនជាប់ចោទឈ្មោះ [redacted] គឹមហូ ឆ្លើយថាៈ ខ្លួនទទួលស្គាល់ថា ខ្លួនពិតជាបានប្រព្រឹត្តដូចក្នុងអង្គហេតុមែន ចំពោះសេចក្តីសម្រេចនៃសាលដីកា ខ្លួនសុខចិត្តទទួល, តែមូលហេតុខ្លួនប្តឹងទាស់ដើម្បីសុំបន្ធូរបន្ថយសំណង ខ្លួនសុំសងចំនួន ១.៥០០.០០០រៀល (មួយលានប្រាំសែនរៀល) ខ្លួនសុំសងឥឡូវនេះ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទី ឆ្លើយថាៈ ខ្លួនសុំដូចសាលាដំបូងខេត្តកំពត តែបើខាងគាត់សុំបន្ធូរបន្ថយ និងសុំបង់ខ្លួនចំនួន ១.៥០០.០០០រៀល (មួយលានប្រាំសែនរៀល) ខ្លួនសុខចិត្តទទួលយក។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

សូមក្រុមប្រឹក្សា ពិចារណា និងសម្រេច តាមការព្រមព្រៀងរបស់ភាគី។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] គឹមហូ,

ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍

## យល់ឃើញថាៈ

១. បណ្តឹងទាស់លេខ ៦៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] គឹមហូ ជាជនជាប់ចោទធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. នៅសវនាការសាលាឧទ្ធរណ៍ ជនជាប់ចោទបានសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តដូចក្នុងអង្គហេតុមែន, តែខ្លួនប្តឹងទាស់នឹងសាលដីការបស់សាលាឧទ្ធរណ៍នេះ គឺដើម្បីសុំបន្ធូរបន្ថយសំណង ដោយសុំបន្ថយពី ៣.០០០.០០០រៀល (បីលានរៀល) មក ១.៥០០.០០០រៀល (មួយលានប្រាំសែនរៀល) វិញ ហើយដើមបណ្តឹងរដ្ឋប្បវេណីបានយល់ព្រមទទួល។

៣. សាលដីកាព្រហ្មទណ្ឌលេខ ៥០ ក្រ.III.ស ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍សម្រេចមានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចសំណង គប្បីសាលាឧទ្ធរណ៍សម្រេចតាមការព្រមព្រៀងរបស់ភាគី។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងទាស់លេខ ៦៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] គឹមហូ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមច្បាប់។



Scanned with CamScanner

២. តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៥០ ក្រ.III.ស ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែចំណុចសំណង ត្រូវកែប្រែមកជា ១.៥០០.០០០ រៀល (មួយលានប្រាំសែនរៀល) វិញ ។ ក្រៅពីនេះទុកនៅដដែល។

សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី, បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា: [redacted] |

.....................................................................................................................................

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ...១២ ខែ ...៦... ឆ្នាំ ២០១៤
ក្រឡាបញ្ជី



Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**************

**សាលាឧទ្ធរណ៍**

**************

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៥៥៧ /០៨.៩.២០០៩

ភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤

**ដីកាសម្រេច**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះទី ៣**

- បានឃើញ មាត្រា ៦០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៥៥៧ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍។
- បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៨៤ ក្រ.III.ស ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍។
- បានឃើញ សាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ ៥០ ក្រ.III.ស ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍។

ក្រោយពីបានពិនិត្យសាលដីកាខាងលើឡើងវិញឃើញថា: សាលដីកាលេខ ៨៤ ក្រ.III.ស ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ មានកំហុសដោយអចេតនា ក្នុងទំព័រទី២ នៃសាលដីកា, ចំណុចទី៣ នៃផ្នែកសំអាងហេតុ និងចំណុចទី២ នៃសេចក្ដីសម្រេច ដោយចុះកាលបរិច្ឆេទ នៃលេខសាលដីកាព្រហ្មទណ្ឌកំបាំងមុខរបស់សាលាឧទ្ធរណ៍ខុស គប្បីសាលាឧទ្ធរណ៍កែតម្រូវឡើងវិញ។

**ហេតុដូច្នេះ**

**សម្រេច**

កែតម្រូវកាលបរិច្ឆេទ នៃលេខសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ក្នុងទំព័រទី២ នៃសាលដីកា, ចំណុចទី៣ នៃផ្នែកសំអាងហេតុ និងចំណុចទី២ នៃសេចក្ដីសម្រេច របស់សាលាឧទ្ធរណ៍ ដូចខាងក្រោម:

សាលដីកាព្រហ្មទណ្ឌលេខ៥០ ក្រ.III.ស ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ទៅជា សាលដីកាព្រហ្មទណ្ឌលេខ ៥០ ក្រ.III.ស ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ វិញ។

ចៅក្រមប្រឹក្សា
ហត្ថលេខា: [redacted]

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខា: [redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner